# ការសម្ភាសន៍របស់អ្នកមីង ឡុង មុំ

**កៈ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិន្ទ ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះឡុង មុំ**

## ពត៌មានសង្ខេបរបស់អ្នកមីងឡុង មុំ

សព្វថ្ងៃនេះអ្នកមីងឡុង មុំមានអាយុ៥៧ឆ្នាំហើយ គាត់មានស្រុកកំណើតនៅខេត្តសៀមរាបតាំងតែពីគាត់កើតមកម្លេះ គាត់មានបងប្អូនចំនួន៧នាក់ហើយគាត់ជាកូនទី២នៅក្នុងក្រុមគ្រួសាររបស់គាត់។ កាលពីក្មេងអ្នកមីងមិនសូវបានរៀនសូត្រជាទៀងទាត់ទេដោយសារតែឪពុកគាត់ធ្វើទាហានហើយត្រូវផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតជាញឹកញាប់។ កាលពីសម័យប៉ុល ពតគាត់ត្រូវបានប៉ុល ពតនាំក្រុមគ្រួសារគាត់ដើររុកព្រៃព្រមជាមួយនិងក្រុមគ្រួសារជាច្រើនទៀតឲ្យតែធ្លាប់ធ្វើជាទាហាន គោលបំណងពួកគេគឺចង់សម្លាប់ពួកគាត់ចោល តែពួកគាត់បានរួចផុតហើយក៏ជម្លៀសទៅភូមិល្វែងឫស្សី។ តែជាអកុសឪពុករបស់គាត់ត្រូវអាពតយកទៅសម្លាប់ឲ្យទាល់តែបានព្រោះឪពុករបស់គាត់ជាអ្នកចេះដឹងមួយរូបដែរ ហើយធ្លាប់ធ្វើជាទាហាន។ ក្រោយមកគាត់ចប់សម័យប៉ុល ពតចាប់ផ្តើមមានក្រុមគ្រួសារ ហើយធ្វើការងារជាអ្នកនេសាទដើម្បីចិញ្ចឹមជីវិត។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់មីងដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់មីង ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់មីងអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាមីង បាទ ហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍មីងចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់មីងណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodianoralhistoryproject.byu.edu ណាមីង ចឹងតើមីងយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់មីងចូលទៅក្នុងវេបសាយរបស់សាលាទេមីង?

ខៈ បានយល់ព្រម។

កៈ បាទសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍មីងនេះគឺ នៅថ្ងៃទី០៥ ខែវិច្ឆកា ឆ្នាំ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិចុងឃ្នាស សង្កត់ចុងឃ្នាស ស្រុកសៀមរាប ខេត្ត

សៀមរាបណាមីង ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិន្ទ អញ្ចឹងខ្ញុំចង់សួរថាតើមីងមានឈ្មោះពេញឈ្មោះអ្វីដែរមីង?

ខ៖ ឡុង មុំ។

ក៖ ចុះអ្នកមីងមានឈ្មោះហៅក្រៅទេអ្នកមីង?

ខ៖ ហៅរហូតចឹងឯងឈ្មោះទាំងក្នុងទាំងក្រៅ

ក៖ ចង់និយាយថាអ្នកខ្លះគេមានឈ្មោះហៅក្រៅ។

ខ៖ នៅក្រៅផ្សេង នៅក្នុងបញ្ជីរជាតិផ្សេងតែមីងអត់ទេមីងតែប៉ុណ្ណឹងឯង។

ក៖ ហើយឆ្នាំនេះមីងមានអាយុប៉ុន្មានហើយមីង?

ខ៖ អាយុ ៥៧ឆ្នាំ។

ក៖ ចុះមីងចាំថ្ងៃខែឆ្នាំកំណើតមីងបានទេ?

ខ៖ អឺអត់ចាំបានទេ ចាំតែកើត ចាំតែកើតថ្ងៃសៅរ៍ កើតថ្ងៃសៅរ៍ឆ្នាំថោះ ចាំតែប៉ុណ្ណោះឯង។

ក៖ ឆ្នាំបារាំងអត់ចាំទេ?

ខ៖ អត់ចាំទេឆ្នាំបារាំងនោះយើងពីដើមមិញយើងសុទ្ធតែខ្មែរមានបានចាំបារាំងអី មួយជំនាន់យើង។

ក៖ ចុះអ្នកមីងមានស្រុកកំណើតនៅឯណាដែរអ្នកមីង?

ខ៖ ស្រុកកំណើតនៅចុងឃ្លៀសនេះឯង។

ក៖ តាំងពីដំបូងម៉ង?

ខ៖ តាំងពីដំបូងម៉ែឪជីដូនជីតានៅនេះឯង។

ក៖ ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖ បងប្អូន៧នាក់។

កៈ ហើយមីងជាកូនទីប៉ុន្មានដែរ?

ខៈ កូនទី២។

កៈ ហើយមានបងប្អូនស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរមីង?

ខៈ ប្រុស២ ស្រី៥។

កៈ ស្រី៥ ប្រុស៣ចឹងនោះ។

ខៈ ប្រុស២។

កៈ ទាំងអស់៧នាក់ហី?

ខៈ អឺ។

កៈ ចឹងទាល់តែប្រុស៣ ស្រី៥ បាន៧។

ខៈ អឺ៥ ត្រូវហើយ៥ ស្លាប់អស់២សល់២។

កៈ ចឹងមីងអាចជួយរៀបរាប់ប្រាប់ឈ្មោះបងប្អូនអ្នកមីងបានទេទាំងអ្នកស្លាប់ អ្នករស់ណាមីង រៀបរាប់មកតាំងពីបងគេរហូតដល់ពៅគេ?

ខៈ ម៉ៅ បងគេឈ្មោះម៉ៅ ប្អូនគេឈ្មោះរ៉េត អេម៉ៅរួចមីងណា មីងរួចអារ៉េត អារ៉េតរួចអាស្នា អារ៉េតរួចមិនទូច មីទូចរួចអាស្នា អាស្នាហើយដារី ប៉ុណ្ណោះឯង។

កៈ ចុះមីងកាលពីក្មេងៗមីងចងចាំអ្វី? ឬធ្លាប់បានធ្វើអ្វីខ្លះដែរជាមួយបងប្អូន?

ខៈ អត់ អត់ដែលធ្វើអី គ្រាន់តែយើងជំនាន់អាពតយើងជីកក្តាមជីកកង្កែបអីយកមកឲ្យប្អូនស៊ីម្តាយស៊ី ពេលដែលយើងទៅធ្វើការជំនាន់អាពតស្ទូងខែស្ទូងយើងចាប់ក្តាមចាប់ត្រីដាក់ថ្នក់សំឡុយ ឬក៏បំពង់ទឹកត្នោត យកផ្ញើរម្តាយយើងប្អូនយើងស៊ី កំសត់ណាស់។

កៈ ចុះកាលសម័យប៉ុល ពតណឹងអ្នកមីងគេជម្លៀសពីចុងឃ្លាសនេះទេ ឬក៏អ្នកមីងនៅនេះដដែលមីង។

ខៈ ជម្លៀសទៅដល់អឺ ល្វែងឬស្សី។

កៈ ទៅនៅតែកន្លែងណឹងមួយទេ ឬដូរកន្លែងផ្សេងទៀតមីង?

ខៈ អឺកាលពីជម្លៀសទៅ វាឲ្យដើររុកព្រៃវាព្រោះឪពុកមីងទាហានគាត់ធ្វើទាហានណា ដល់ពេលធ្វើទាហានទៅប្រពន្ធទាហានណឹង ប្រពន្ធទាហានណឹងប្ដីទាហានណឹងវាឲ្យដើររុកព្រៃទាំងអស់គ្នាវាអត់ឲ្យចូលស្រុកទេ តាមថ្នល់ជាតិវាអត់ឲ្យដើរដែរវាឲ្យរុកព្រៃ ព្រៃយើងតាមភ្នំដងរែកទល់ដែនថៃណា ណឹងទល់ដែនថៃហើយឲ្យដើររុកនោះ ដើររែកឥវ៉ាន់ទៅយប់ត្រឹមណាឲ្យដេកត្រង់ណោះ ជួនណាដេកបាន២ថ្ងៃ ២យប់ ជួនណាដេកបានមួយយប់ទៅទៀតហើយរែកទៀតហើយរែករហូត ទៅក៏ចាប់ក្ដាមចាប់ខ្យងអីស៊ីតាមផ្លូវណា ហើយអង្ករគេចែកក្នុងមួយគ្រួសារ៣កំប៉ុង ហើយមួយគ្រួសារ ៧ ៨នាក់ ១០នាក់ ប្រហែលចូល១០នាក់ ហូបមិនឆ្អែតក៏គាស់ដំឡូងជីកដំឡូងជីកអីមកផ្សំណា២នាក់ឪពុក ប៉ារែងយកខ្ញុំទៅព្រៃណាស់ដល់ពេលបោះជុំរុំនៅក្នុងព្រៃណឹងទៅ តង់ណឹងណាបោះតង់ក្នុងព្រៃទៅក៏នាំកូនទៅដើរស្រវាខ្មៅស្រវាគ្រុំនៅអូរទល់ដែនថៃ ទល់ដែនថៃហើយនោះ ខ្លា ដំរីទៅថ្ងៃណាទៅក៏វាដើរទៅដើរទៅទៀតដាក់ត្រង់ណាដេកត្រង់នោះព្រៃណាដែលរុកមិនរួចឲ្យប្រុសៗឆ្ការព្រៃរុកទៅទៀតចុះមីងអាយុ១២ឆ្នាំមីងមិនដឹងម៉េច ឆ្ការព្រៃរុកដើរព្រៃទៅទៀតអឺយប់ត្រង់ណាដេកត្រង់នោះ អរព្រៃត្រង់ណាដែលមានភូមិជិតភូមិណា ម៉ែម៉ែមីងទៅហើយវិច ដូចជាមានសម្ភារៈដូចអង្ករដូចថាយើងមានរបស់ល្អៗណាដូចថាមាសប្រាក់តិចតួចវិចខ្ចប់ទៅដូរអង្ករស៊ី វាឃើញតែវាឃើញវារ៉ៃចោលទៀតទៅសុទ្ធតែលួចលាក់សុទ្ធតែរត់ យ៉ាប់ណាស់អូនឯងអត់ដឹងទេមីងនិយាយតែការពិតពេលណាវាឃើញយើងវារ៉ៃយើងចោលឃើញយើងមានអង្ករណា លាក់ខ្ចប់វិចអត់ឲ្យវាឃើញទេ គ្រាន់តែមីងដើរក្នុងព្រៃដែលប៉ាគាត់តែងតែនិយាយដើរក្នុងព្រៃណឹង ងាប់ចង់ពាក់កណ្ដាលអត់បាយស៊ី។

កៈ ចុះពេលមីងទៅក្នុងព្រៃណឹងប៉ុល ពតអ្នកនាំទៅមែនទេមីង?

ខៈ ប៉ុល ពតអ្នកនាំទៅ ប៉ុល ពតវាអ្នកនាំឲ្យយើងដើរទៅ មួយខ្សែៗដល់ពេលណាល្ងាចស្នាលណាគេចែកអង្ករឲ្យស៊ីទៅ ២ ៣កំប៉ុងទៅណាក៏យកមកបបរលាយដើមចេកអីទៅ ផ្សិតនិយាយទៅក្នុងព្រៃសំបូរផ្សិត ផ្សិតតាមដំបូកណាបេះផ្សិតមកលាយបបរស៊ីទៅហើយយើងនៅក្មេងផងមិនដឹងឯណាឯណីផងចេះតែសប្បាយទៅណា អត់ដឹងខ្យល់អីទេចេះតែសប្បាយមិនដឹងអ្នកណារ៉ៃអ្នកណាចោលទេ ថ្ងៃមួយនៅឯជំរុំក្នុងព្រៃលឺប៉ាគាត់ខ្សិបគ្នាជាមួយឪពុកមារ មារថាន់ មារសុខ ៤ ៥នាក់ណា ១២នាក់ ទាំងញាតិមិត្តជិតខាងយប់ឡប់ឡងនាំគ្នារត់ រត់ចូលថៃ បបួលប៉ានេះរត់ថារ៉ុមឯងយើងនៅមិនរស់ទេយើងរត់ទៅដឹងម៉ាអាយើងនៅជិតទល់ដែនរត់តិចទៅដល់

ហើយ ប៉ាខ្ញុំថាគាត់មិនទៅទេហ្អែងចង់ទៅទៅតែហ្អែងទៅអញអត់ទៅចោលប្រពន្ធអញទេ ហាសហ្អែងមើលនៅក្នុងព្រៃប្រពន្ធកូនយើងដើរតាមណាបើមិនមានយើងជាប្រុស ប៉ាអត់បានទៅទេ បងប្អូននាំគ្នារត់ គេបាញ់ចោលឬម៉េចបាត់ដំណឹងរហូតវាតាមបាញ់តាមពីក្រោយ តាមបាញ់យើងទៀតណាអាអូន វាដឹងថាយើងរត់វាព្រឹបៗៗតាមបាញ់យើងងាប់ពេញក្នុងព្រៃ អ្នកដែលរត់ទៅរួចដល់ថៃសុទ្ធតែពីគ្រាប់កាំភ្លើងរួចហើយ អ្នកដែលមិនបានទៅដល់ងាប់ចោលក្នុងព្រៃ មារថាន់ មារសុខ មារមីងនោះឯង ប៉ាសំណាងល្អគាត់អត់ទៅវាឲ្យដើរទៅទៀតទៅដើរយប់ត្រង់ណាដេកត្រង់នោះ មានខ្យងស៊ីខ្យងមានក្តាមស៊ីក្តាមទៅ ដល់ប៉ាគាត់ថាដើរ១ខែ២០ថ្ងៃគ្រាន់តែដើរក្នុងព្រៃណាចេញពីស្រុកយើងទៅណា ១ខែ២០ថ្ងៃវាឲ្យយើងដើរទៅងាប់តែយើងមិនងាប់ វាឲ្យតែប្រពន្ធទាហានណឹងគឺថាវាឲ្យដើរក្នុងព្រៃរហូត បើអ្នកស្រុកអត់មានទាហានវាអត់ធ្វើអីទេវាឲ្យនៅក្នុងស្រុក បើយើងប្រពន្ធទាហានវាឲ្យដើររុកព្រៃ ដើរបាន១ខែ ២ថ្ងៃបានវាហៅប្រជុំឲ្យចូលស្រុក ចូលស្រុកភូមិគេ អឺបងប្អូនអើយដល់ទិសដៅយើងហើយ មិត្តស្អែកឡើងណឹងមិត្តឯងរទេះគេមកយកហើយ មិត្តណាជិះរទេះណាជិតទៅរទេះណានាំដាក់ភូមិដាក់នៅភូមិណឹងទៅ ស្អែកឡើងរទេះគេមកព្រឹបៗទៅណាមីងឡើងរទេះនិងគេឡើងថ្នល់ជាតិ អូបានឃើញថ្នល់ជាតិនិងគេហើយ បានឃើញថ្នល់ជាតិជិះៗទៅដល់គេហៅវត្ត វត្តតាអុងហីវត្តណឹងចុះទៅផ្លូវចុះទៅភូមិល្វែងឬស្សីណឹងឯង ក៏អ្នកណាគេនៅភូមិតាអុង តានួនអីគេទៅអស់ហើយណារទេះគេយកដាក់តាមភូមិមីងចាំភូមិល្វែងឬស្រីណឹងឯង ទៅៗវាឲ្យយើងទៅធ្វើស្រែ ធ្វើស្រែព្រលឹមឡើងទៅធ្វើស្រែទៅត្រូវច្រូតៗទៅកាត់ៗទៅណា រែកអាចម៍ជីរែកដីជីទៅណាមីងអាយុ១២ឆ្នាំក៏មីង ក៏គេឲ្យទៅធ្វើដែររែកអាចម៍ជីទៅរែកអីទៅ និងគេនិងឯងទៅ ទៅព្រៃក៏មកដល់ក៏ស៊ីបាយរួចមួយចានណាបាយឲ្យមួយចានប៉ុណ្ណេះៗបាយ អស់មួយចាអត់មានអីស៊ីទៀតទេ ទៅពេលយើងទៅធ្វើការទៅក៏យើងដើររើសខ្យង រើសក្តាមក្នុងទឹកទៅណា យកមកស្ងោរប្រលាក់អំបិលស៊ីទៅ មិនដែលស្គាល់ជាតិម៉េចប៊ីចេងទេ ទៅក៏ស្រាប់តែធ្វើការទៅអូថ្ងៃត្រង់ថ្ងៃរសៀលទៅភ្លៀងខ្យល់មកទៅជួនណាខ្យល់បាំងធ្លាក់ពីលើភ្លឺស្រែក៏មានដែរខ្យល់ទឹកវិញសុទ្ធតែឈ្លើងអើយអញអើយលាត់ជើងខោសព្វថ្ងៃអត់ខ្លាចឈ្លើងណាចុះសុទ្ធតែឈ្លើងពេក ដល់ត្រូវវ៉ៃមនុស្សដឹកមកទាំងឡាន ផ្ទះមីងចេះឯងគេឲ្យមីងនៅជម្រុកស្រូវនៅជម្រុកស្រូវនេះថ្នល់វាអត់មានផ្ទះនៅនៅតែជម្រុកស្រូវទេ ថ្នល់នេះទៅសាលារៀន ទៅសាលារៀនពេណាដែលសាលារៀនវាមាន៣តង់ សាលារៀនពួកវាពីដើមណា សាលារៀនមាន៣តង់ ពេលវាតត្រូវដឹកមនុស្សមកវ៉ៃចោលវាដឹកមនុស្សមកតាមផ្លូវផ្ទះមីងណឹងឯង ម៉ាឡានៗប្រាប់កូនអើយបុកសុទ្ធតែកាណុងកាំភ្លើង វ៉ៃសុទ្ធតែកាណុងកាំភ្លើងឡើងឡានឲ្យឡើងឡានដឹកទៅកន្លែងនោះឯងដឹកកន្លែងនោះរួច អាមួយនោះឈាមឲ្យរហាច ឲ្យឡើងឡានរួចវាវ៉ៃ អើយវេទនា

ណាស់ មីងអង្គុយហែកអត់ហ៊ានចេញមកមើលទេមីងអង្គុយហែកជញ្ជាំងមើលទេ ចុះមីងជាងប់និងផ្លូវនោះឯងផ្លូវកែងវាបត់ចូលចេះ ចេះឯងផ្ទះមីងនៅនេះមីងលួចមើលតាមជញ្ជាំង ចងសុទ្ធតែព័ទ្ធស្លាបសេក ប៉ុនៗអូនឯងណឹងសិស្សសាលាក៏មានទាហានក៏មានឲ្យតែអាណាខុសចងដាក់ក្នុងនោះឯង ដាក់មួយយប់ស្អែកឡើងបានដឹកដឹកទៅវៃចោល បានរំលង ៤ ៥ថ្ងៃកន្លះខែមាន១ឡានមកទៀតហើយ បានរំលង ៤ ៥ថ្ងៃកន្លះខែមាន១ឡានមកទៀតហើយដឹកទៅវៃចោលក្មេងៗ មិនហ៊ានចេញមកមើលក្រៅលួចហែកជញ្ជាំងមើល ចង្រៃចៃដ្យន្ទអីគេចាប់ម៉ែមីងម្តង។

កៈ មូលហេតុអីបានគេចាប់ដៃរអ្នកមីង?

ខៈ កំសត់ណាស់ណា ម៉ែគេឲ្យទៅធ្វើការនៅមាត់ខ្លារធ្វើត្រីមាត់ខ្លារដល់ទៅធ្វើទៅឆ្នាំណឹងគេប៉ះបោរ ប៉ះបោរអ្នកណាគេចង់គេឃើញអាពតសម្លាប់ច្រើនពេកគ្នាវាណឹងឯងក្រុមគ្នាវាណឹងឯង ដល់ពេលក្រុមគ្នាវាឃើញវាឃោរឃៅខ្លាំងពេកក៏មានគ្នាប៉ះបោរ ប៉ះបោរជិះសុទ្ធតែសេះជិះសេះកាប់ ម៉ែគាត់និយាយណាម៉ែគាត់ទៅមកវិញគាត់និយាយនេះម៉ែគាត់និយាយប្រាប់ កូនប្រាប់គេបានគេចាប់ម៉ែយកទៅវៃចោលដែរ អូនអើយជិះសេះនិយាយតែគ្នាឯងមួយក្រុមណឹងមនុស្ស២នាក់ ២គ្រួសារនិយាយប្រាប់គ្នាឯងខ្សិបៗមិនហ៊ាននិយាយខ្លាំងទេ បើនិយាយខ្លាំងគេវៃយើងចោល ខ្សិបប្រាប់ថាអញរត់មករហេមរហាមណាស់ មីរិនអើយសុទ្ធតែជិះសេះកាប់គ្នាជិះសេះកាប់គ្នាណាអាអូន ដល់ពេលដល់ពេលគ្នាចង់រំដោះប្រជាជនឲ្យចេញពីក្នុងដៃវាសម្លាប់ពេកធ្វើអត់កើតធ្វើអត់កើតទេ គេអ្នកដែលនាំប៉ះបោរមេនាំប៉ះបោរណឹងគេយកទៅវៃចោលទាំងអស់ មេនាំប៉ះបោរណា លោកអីលោកសុខលោកសុនណានោះ ខ្ញុំភ្លេចឈ្មោះហើយម៉ែតែងនិយាយឈ្មោះណឹងលោកណាទេដល់ពេលគាត់នាំប៉ះបោរទៅទៅអត់រួចគេដឹងមុន គេដឹងទាន់ ហើយពេលដឹងទាន់ជិះសេះកាប់យកគ្នាបណ្តោយប្រាប់ទៅសាហាវណាស់ម៉ែគាត់និយាយ សាហាវណាស់អូនប្រាប់អូនឯងអូនឯងអត់ដឹងទេ ដល់ពេលគ្នាប្រុងប៉ះបោរ ប៉ះបោរអត់ទាន់គេកាប់ទាន់យកអាអ្នកប៉ះបោរទៅវៃចោលអស់រលីង វៃចោលទាហានចាប់ទាំងឡានៗមុនដំបូងវៃទាហានទេណាវៃទាហានចោលទេ ស្រាប់តែពេលប៉ះបោរក្រឹប ប៉ះបោរអត់ឈ្នះគេនេះលោកក្រោយសុទ្ធតែសិស្សសាលា មារមីងមួយ ក្មេងប៉ុនកូនឯងរៀនចប់ថ្នាក់ អង់គ្លេសបារាំងរិល ដល់ពលវាដឹងថាប៉ះបោរអត់កើតតវាចាប់សិស្សសាលាយកទៅវៃចោលម្តងឲ្យតែអាណាចេះវៃចោល ឲ្យតែអាណាចេះអក្សរវៃចោល អាណាចេះអក្សរចូលទាំងឡានៗប្រាប់កូនឯង សាហាវណាស់ទាំងឡានៗមារមីងពីមុនអត់អីទេគេចាប់ទាន់វៃចោលណា ដល់ពេលប៉ះបោរអត់បានសម្រេចគេដឹងការរណ៍ទាន់ នេះវាស្រាវជ្រាវចាប់សិស្សសាលាម្តង សុទ្ធតែសិស្ស

សាលាទៅវ៉ៃចោលអើយទាំងឡានៗ ៤ ៥ឡានៗ គេយកទៅវ៉ៃចោលឯងណាហាសម្បើមម្ល៉េះយើង យើងនៅអាអង្គរអានៅផ្លូវទៅអង្គរនោះគេហៅអីគេពីមុននោះដែលតែងទាហាននៅ អាផ្លូវយើងទៅអង្គរនោះដែលទាហាននៅពីដើមអាកន្លែងស្អីគេដែលកុមារកំព្រារនៅកុមារកន្លែងគេធ្វើពេទ្យកុមារសព្វថ្ងៃណា អញប្រាប់មួយអណ្តូងៗពេញសុទ្ធតែមនុស្សគ្រប់អណ្តូង មីងអត់ដឹងទេមីងអត់ដឹងគេយកទៅវ៉ៃចោលត្រង់នោះទេណាហើយមីងចង់និយាយថារួចទៅមីងចង់និយាយថាយើងចូលស្រុកហើយណាអ្នកទន្លេយើងណឹងប៉ះបោរទៅស្រវារមាស ស្រវារមាសនៅឯណាស្រវារមាសក្នុងអណ្តូងគេបានមាសចុះគេយកមនុស្សទៅវ៉ៃចោលក្នុងណឹងនោះ អាខ្លះពាក់ខ្សែករពាក់ខ្សែដៃអាខ្លះនៅចង្កេះនៅអីលាក់ទុកណា លាក់ទុកគេទៅស្រវារកឃើញមាសឡើងបានមិនចេះតិចមួយៗ អូនអើយមិនដឹងប៉ុន្មានអណ្តូងទេមិនបានសួរបញ្ជាក់មិនដឹងប៉ុន្មានអណ្តូងសុទ្ធតែខ្មោច សង្ស័យតែខ្មោចសិស្សសាលាសារក្រោយហើយនេះសិស្សសាលាសារក្រោយនេះ ស្រុកមីងណាសម្លាប់ចោលឡើងស្វាត់នៅតែស្រីៗនេះចុងឃ្នាស គេថាចុងឃ្នាសណឹងយោរយៅរណាស់ ស្វាយត្រនពីមដើមមិញចុងឃ្នាសយើងវិន័យតឹងណាមានទាហានស្វាយត្រានយាមតាភូមិវាចូលវ៉ៃចូលចុងឃ្នាសអត់បានទេ វាគុំណាស់កូនអើយដល់ពេលវារំដោះបានវាលេងអ្នកចុងឃ្នាសឡើងអស់ប្រុសៗសល់តែស្រីៗ ឲ្យតែថាសិស្សសាលាប៉ុនណាវ៉ៃចោលទាំងអស់ឲ្យតែគ្រប់អាយុវ៉ៃចោលឲ្យតែអ្នកចេះអ្នកចេះដឹងវ៉ៃចោលទាំងអស់មារមីងប៉ុន្មាននាក់រួចខ្លួនអស់ហើយណឹងជិតវ៉ៃដាច់ហើយណឹងជិត៧៧ហើយណា យើងវ៉ៃដាច់៧០ន្នាន?

ក៖ ៧៩។

ខ៖ យើងជិតវ៉ៃដាច់ហើយណឹងអាអូនឯងមើលណាខុសគ្នាតែមួយឆ្នាំសោះណាវាប្រមូលវ៉ៃចោលទាន់ពេលវេលាវាប្រមូលវ៉ៃចោលឡើងព្រឹបៗមិនថាតែយើងទេបាត់ដំបង បាត់ដំបងសុទ្ធតែវ៉ៃដែកគោលតាមដៃ បាត់ដំបងសាហាវដែរណាសម្លាប់ ខាងបាត់ដំបងក៏សាហាវដែរក៏វ៉ៃមនុស្សសាហាវដែរសុទ្ធតែដែកគោលវ៉ៃតាមដៃប្រាប់អូនឯង អាក្រក់ណាស់បានប្រាប់កូនចៅកូនអើយកើតមិនទាន់ជំនាន់អាពតទេ មីងដល់ពេលបើកទូរទស្សន៍ចំជំនាន់អាពតមីងអង្គុយមើលណាកម្សត់ពីដើមមិញវែកដីវែកអីថតដាក់ទូរទស្សន៍ដែលហ៊ុន សែនដាក់ឲ្យមើលមិនមានវែកដីវែកអីអញមើលស្រណោះអញពីដើមមិញចឹងឯងវែកដី អាយុ១២ឆ្នាំមាឌល្អិតផងប្រើអញដូចគោចឹង។

ក៖ ចុះកាលសម័យប៉ុល ពតណឹងមីងបាត់បង់សមាជិកគ្រួសារណាខ្លះដែរមីង?

ខ៖ ច្រើន ប៉ាមួយ មារនោះ៥នាក់ អូច្រើនបើរាប់ទៅច្រើន។

ក៖ ចុះបងប្អូនមានបាត់បង់សម័យប៉ុល ពតទេមីង?

ខ៖ បាត់ប្អូនអត់មានបាត់ទេនៅតូចៗនោះ តូចៗអាយុមើលមីង១២ឆ្នាំណឹងបងប្អូនមីងតូចៗ ណឹងមានបាត់បង់អី បាត់បង់តែឪពុកណឹង។

ក៖ ចុះម្ដាយរបស់មីងមានឈ្មោះអ្វីដែរមីង?

ខ៖ ម៉ែខ្ញុំនៅរស់ទេចាំមើលមីងនិយាយដំណាលមីងនិយាយម៉ែខ្ញុំឈ្មោះតួន ឡៃ ទៅដល់ពេល គេយកម៉ែយើងទៅវ៉ៃចោលគាត់មកដល់គាត់និយាយពាក្យណឹងណា លឺដល់គេគេយកដាក់ម៉ែ ខ្ញុំម៉ាឡានទៅច្រកកន្លែងនោះឯងតាមផ្លូវទៅផ្ទះណឹងឯង អាណឹងអាយោធាណឹងឈ្មោះវាអា ពោលាក់អ្នកត្រូវវ៉ៃគេចោលឈ្មោះវាអាពោលាក់មិនដឹងថាវាអ្នកវ៉ៃឬក៏វាមកចាំដឹកទៅទេណា ដល់ពេលទៅដល់ចាស់ៗសំពះអង្វរករទៅអ្នកស្រុកភូមិណឹងគេ ស្រណោះអាណិតមេម៉ាយៗ ណា ប្រហែលជា១០នាក់មេម៉ាយៗ ទៅក៏ចាស់ៗអ្នកភូមិណឹងអ្នកចាស់គេណាគេស្រណោះ អាណិតម៉ែដឹងខ្យល់អីគ្នាក៏ចាស់ៗក៏ជួយសំពះអង្វរទៅទាំងអស់គ្នាទៅគេលែងមួយឡានមក វិញកុំអីម៉ែយើងគេវ៉ៃចោលបាត់ គ្រាន់តែយើងនិយាយថាពាក្យអូជិះសេះកាប់គ្នាគ្រាន់តែ ប៉ុណ្ណឹងសោះ។

ក៖ ចុះម្ដាយរបស់អ្នកមីងជាមនុស្សបែបណាដែរមីង? គាត់កាចឬក៏ស្លូតដែរមីង?

ខ៖ ម៉ែខ្ញុំស្លូតទេ នោះឈឺដេកកន្ទេលនៅផ្ទះបង ផ្ទះបងបង្កើត។

ក៖ ចុះឪពុករបស់អ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឪពុកឈ្មោះរ៉ុម ចាសមិនដឹងស្អីរ៉ុមទេភ្លេចត្រកូលប៉ាបាត់ទៅហើយ។

ក៖ ចុះគាត់ណឹងជាមនុស្សបែបណាដែរអ្នកមីង? គាត់កាចឬក៏ស្លូតដែរ

ខ៖ ស្លូតណាស់ ស្លូត ស្លូតហើយសុភាព ស្លូតហើយសុភាពគាត់សិស្សសាលាគាត់ឈប់រៀន គាត់ចូលធ្វើទាហានរហូតតែពីក្មេងរហូតដល់កូន៧នាក់ គាត់ធ្វើទាហានរហូតទាល់តែអាព តយកទៅវ៉ៃចោលតិចឆ្នាំណាស់ឡើងមានកូន៧នាក់នោះ។

ក៖ ចឹងមានន័យថាគាត់ជាអ្នកមានរៀនសូត្រជ្រៅជ្រះ?

ខ៖ អ្នកចេះដឹងណាអីធ្វើការ សុទ្ធតែខាងវាលកប៉ាល់ហោះ អីបឹងកាឡូយើងនៅភ្នំពេញគាត់ធ្វើការគ្រាន់បើបស់គាត់ដែរណាគាត់ទៅណាមានគេគោពរ ណឹងហើយគាត់ធ្វើការធំដែរណាប៉ាពីដើមណាចុះគាត់ធ្វើទាហានមិនតិចឆ្នាំឯណាហើយបើឡើងវ៉ៃវិញមិនដែលត្រូវគ្រាប់តិចទេស្មោង យើងដឹងថាប៉ាឡើងវ៉ៃនៅស្មោងដែលធំដឹងក្តីឡើងអាយុប្រហែលជា៧ ៨ឆ្នាំ វ៉ៃបាញ់គ្នានៅស្មោងយួនចាប់គេលែងមកវិញបែបគាត់ស្លូតពេកយួនចាប់គេលែងមកវិញ នៅយ៉ាកកុងណា អូនមិនដឹងទេយ៉ាកុងទម្លាក់គ្រាប់បែកពេញនេះឯងប៉ាគាត់ធ្វើទាហានណា គាត់តស៊ូណាស់ប៉ានោះពេលឡើងវ៉ៃត្រង់ណាមិនដែលថាត្រូវរបួសបន្តិតទេឆ្ងល់គាត់ហើយដើរតែវ៉ៃដើរតែបាញ់ណាហើយនៅជំនាន់នោះមិនសម្បូរសង្គ្រាមហាស ជំនាន់នោះសំម្បូរសង្គ្រាមណាស់ងាកភ្នំពេញងាកនោះក្នុងព្រៃយកមីងទៅនៅក្នុងព្រៃ ផ្លោងគ្រាប់មកចាំដំបូងផ្ទះបែកជំនាញ់អាពតណឹងឯង ដែលគាត់ឡើងទៅវ៉ៃញឹកបែបឡើងអាពតវាអុកឡុកហើយ អាពតវាអុកឡុកបានគាត់ឡើងទៅវ៉ៃញឹកណាស់។

ក៖ ចុះឪពុកម្តាយអ្នកមីងធ្លាប់ប្រាប់សាច់រឿងកាលពីក្មេងៗរបស់គាត់ដល់មីងទេ? ប្រវិត្តគាត់កាលពីក្មេងៗឲ្យមីងដឹងអត់ទេ?

ខ៖ ប្រវិត្តគាត់នោះប៉ាសិស្សសាលា សិស្សសាលាគាត់មកឈប់រៀនគាត់មកគាត់ធ្វើការនៅគាត់នៅតាកែវស្រុកកំណើតប៉ាណា គាត់មិនដឹងគាត់មករៀងនៅឯណាទេបានមកជួបម៉ែណឹងឯង អូគាត់មកធ្វើការ ចាសគាត់មករៀនដល់មករៀនទៅអត់មានលុយទៅគាត់មកធ្វើការនៅឯទន្លេនេះ គាត់ធ្វើការណាធ្វើការចំឪពុកម្តាយ ពុកម៉ែមីងណឹងឯង តាណាអូសត្រីអូសអីណឹងឯងយកលុយទៅរៀន បែបទៅរៀនសៀមរាបដឹងមើលទៅអាយុប៉ុន្មានទេ ១៨ ១៩ដឹង ជំនាន់នោះប៉ា២០ហើយដឹងមិនដល់ទេមើលទៅទៅមកធ្វើការយកលុយទៅរៀន ទៅដល់មកធ្វើការយកទៅរៀនៗៗទៅឃើញម៉ែស្រលាញ់ម៉ែទៅ ទៅក៏ស្រលាញ់ម៉ែទៅអូតាខឹងសុទ្ធតែភ្ជាក់រកកាប់ចោលនោះចាស់ៗមកឃាត់ឡើងប្រសាច បានម៉ែទៅក៏វាយថ្មលើភ្នំទំងន់បងស្រីខ្ញុំទៅក៏តាកាត់ការរាប់ ដេ៉ងទៅនៅត្រង់ណានៅទៅពីដើមមិញគាត់នៅស្រុកមានមុខមានមាត់តា ដល់តែពេលកូនធ្វើចឹងគាត់ខឹងដេ៉ងទៅនៅណានៅទៅដេ៉ងកុំមកនៅផ្ទះអញ ដល់ពេលគាត់ដេញវ៉ៃទៅចាស់ៗមកចាប់ព្រោងព្រាតទៅណា ទៅក៏ឈប់ទៅចាស់ៗអង្វរអូអ្នកស្រុកមកសំពះអង្វរទម្រាំរួចខ្លួនម៉ែខ្ញុំ អ្នកស្រុកនេះនិយាយក្រេវៗដូចថាក្រុមគ្រួសារគាត់អ្នកស្រុកនេះស្រលាញ់ណាស់រហូតដល់ប៉ាខ្ញុំទៀត ទៅក៏នាំប្តីប្រពន្ធទៅបោះរោងនៅឯជើងភ្នំវាយថ្មលក់ ពេលនេះទៅក៏គាត់វាយៗប៉ាគាត់សម្រេចចិត្តទៅនៅបានធ្វើទាហានណឹងឯង ធ្វើទាហានទៅក៏នៅនិងសៀមរាបណឹងឯង។

កៈ ចុះអ្នកមីងចាំឈ្មោះជីដូនជីតាខាងម្ដាយបានទេអ្នកមីង?

ខៈ យាយមឿន តាវ័ន្ត។

កៈ ពួកគាត់ណឹងជាអ្នកចុងឃ្នាសណឹងមែនអ្នកមីង?

ខៈ ចុងឃ្នាសនេះឯង។

កៈ ចុះអ្នកមីងស្គាល់ជីដូនជីតាខាងឪពុកអ្នកមីងទេអ្នកមីង?

ខៈ អត់ស្គាល់សោះតូចពេកមិនដែលស្គាល់ជីដូនជីតាគាត់ផង។

កៈ ដឹងថាពួកគាត់នៅតាកែវមែនទេមីង?

ខៈ ដឹងថាស្រុកគាត់នៅតាកែវ។

កៈ ចុះអ្នកមីងមានបងប្អូនឬក៏សាច់ញាតិដែលរស់នៅក្រៅប្រទេសអត់អ្នកមីង?

ខៈ គ្មានទេកូន មិនមានទេ។

កៈ ចុះស្វាមីរបស់មីងណឹងមានឈ្មោះអ្វីដែរមីង?

ខៈ ព្រែក។

កៈ ចឹងអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីណឹងនៅឆ្នាំណាដែរអ្នកមីង?

ខៈ ២៥ឆ្នាំហើយ ២៦ឆ្នាំហើយ។

កៈ ការរៀបអាពាហ៍ពិពាហ៍របស់អ្នកមីងណឹងត្រូវបានរៀបចំឡើងដោយឪពុកម្ដាយ ឬរៀបចំឡើងដោយចិត្តខ្លួនឯងដែរអ្នកមីង?

ខៈ ឪពុកម្ដាយ។

កៈ ហើយចឹងអ្នកមីងអាចប្រាប់បានទេពីពេវេលាដែលអ្នកមីងជួបស្គាល់គ្នាជាមួយស្វាមីណឹងស្គាល់គ្នាដោយរបៀបណាហើយម៉េចបានស្រលាញ់គ្នាដែរចឹងអ្នកមីង?

ខ៖ មីងអាយុ៣១ឆ្នាំមីងទិញត្រីទិញប្រហុកមីងទិញឥវ៉ាន់លក់ឯព្រៃ នៅព្រៃណាមីងទិញឥវ៉ាន់លក់នៅឯព្រៃមកវិញមីដូរប្រហុក ឥវ៉ាន់យកទៅដូរប្រហុកណាអ្នកណាគេមានលុយឲ្យលុយមកអ្នកណាមានប្រហុកឲ្យប្រហុកមក ដល់ពេលមីងទិញដូរៗគេយូរទៅ អឺឪវានេះគេនៅវាយមង វាយមងជាមួយម្ដាយ មីងនេះអ្នកលក់ឥវ៉ាន់ដល់ពេលមីងទិញៗទៅប្រហុកចេះតែច្រើនវាចេះតែច្រើនទៅក៏មីងយកមកលក់អត់រួចចុះប្រហុកវាច្រើន អ៊ុំទុកម៉េចរួចដើបពីយប់ម៉ោង៣ទៀតវាល់ដងអ៊ុំមករួចដល់ពេលខែប្រាំងវាគោកទឹកអស់អត់មានទឹកអ៊ុំមិនគោក អ៊ុំអើយអ៊ុំរកកូនអ៊ុំឯងមកជួយលក់ប្រហុកមួយថ្ងៃមក រកគេ ម្ដាយគាត់គេស្រលាញ់ខ្ញុំដែរណាបងប្អូនគេឃើញយើងចេះរកស៊ីណាដល់ពេលថ្ងៃណាមីងប្រមូលប្រហុកតាមរោងគេអស់ យប់ណឹងមីងរកពូហ្អែងទៅជួយលក់ប្រហុកហើយទៅជួយដោលទូក វាគឿងសុទ្ធតែរួចអញទៅរុញរួចលើភក់ ចុះខែប្រាំងវាមិនគោកអស់ រុញលើភក់ដល់ពេលរុញៗទៅក៏គេនៅក្មេងនោះអាយុ២១នោះមីងអាយុ៣១ប្ដីមីងអាយុ២១ណឹង តែនោះរូបថតនោះមើលឈរថតជិតមីងមើលអ្នកណាចាស់ជាង។

ក៖ ពូមិញណឹងមែនមីង?

ខ៖ អឺ ខ្ពស់ចង្រ្កាង។

ក៖ ចុះកាលណឹងមីងបានទទួលថ្លៃជំនូនពីលោកពូអត់ទេអ្នកមីង?

ខ៖ អត់ទេកូនបានតែរៀបចំសែនធម្មតា។

ក៖ បាទមីង ចុះអ្នកមីងចេះអាននិងចេះសរសេរអក្សរខ្មែរទេអ្នកមីង?

ខ៖ អត់សូវចេះទេចុះបើថាឪពុកដើរធ្វើទាហានតែរហូតណឹងមានសូវបានរៀនឯណា តិចផ្លាស់ទៅណេះតិចទៅភ្នំពេញ តិចទៅឯណាឯណីដើរម៉ែគាត់ដើរតាមប៉ារហូត ឯងមានចេះអក្សរអីបានរៀនតិចៗណឹង។

ក៖ ចឹងអ្នកមីងបានទៅរៀនដែរមែនអ្នកមីង?

ខ៖ រៀនតែរៀនបានតិចកូនទើបរៀនបានប្រហែលជា២ឆ្នាំ អាពតវ៉ៃគ្រប់បណ្ដោយមករៀនសៀមរាបនេះដល់ពេលគាត់ដើរបាញ់ផ្អែតឆ្អន់ទៅ ផ្លាស់មកនៅសៀមរាបអាដីខាងក្រោយ អាដីជូរមានបានទៅយកអីឯណាមកវិញនោះ។

កៈ ចុះអ្នកមីងមានមិត្តភិក្តដែលស្និតស្នាលដែលធំធាត់មកជាមួយគ្នាទេតាំងពីក្មេងមកដល់ឥឡូវនៅមានទេអ្នកមីង?

ខៈ អត់ហើយ។

កៈ អត់មានទេ?

ខៈ អត់។

កៈ អញ្ចឹងអ្នកមានធ្លាប់ប្រកបអាជីវកម្មលក្ខណៈគ្រួសារដូចជាចិញ្ចឹមគោ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់អីអត់ទេអ្នកមីង?

ខៈ អត់ រកតែត្រី។

កៈ ចឹងអ្នកមីងធ្លាប់ប្រកបការងារអ្វីដែរដើម្បីចិញ្ចឹមជីវិតនិងគ្រួសារអ្នកមីង?

ខៈ រាល់ថ្ងៃនេះ?

កៈ តាំងពីក្រមុំអីចឹងអ្នកមីង? តាំងពីមានគ្រួសារមក?

ខៈ រកតែត្រីកូនអើយ។

កៈ ធ្វើតែនេសាទទេ?

ខៈ ចាស។

កៈ ចុះអ្នកមីងអាចប្រាប់បានទេថាពេលណាដែលអ្នកមីងគិតថាអ្នកមីងពិបាកជាងគេបំផុតក្នុងជីវិតដែរមីង?

ខៈ នេះកំពុងពិបាកហើយនេះ ក្សូណានេះ។

កៈ សព្វថ្ងៃណឹងមែន?

ខៈ កំពុងតែពេញធឹងហើយ។

កៈ ចុះអ្នកមីងអាចប្រាប់ទេថាពេលណាអ្នកមីងសប្បាយចិត្តជាងគេវិញ?

ខ៖ សប្បាយចិត្តពេលដែលបាត់ក្វរ៉ុណា ណឹងមានសប្បយាចិត្ត កូនទើបបានចូលធ្វើការលែង ទើបតែក្វរ៉ូណាភ្លាមកូនអត់មានអ្នកណាធ្វើការទេ ដាច់ពោះអាដំបូងយើងប៉ុន្មានខែណឹង អូលក់ហាលលៀសលក់ត្បាញអង្រឹងលក់មីងណាទម្រាំបានធូរធារឲ្យកូនចូលធ្វើការខ្លះមកវិញណា។

ក៖ ចុះអ្នកមីងតាំងពីក្មេងមកដល់ឥឡូវតើជីវិតអ្នកមីងបានផ្លាស់ប្ដូរអ្វីខ្លះដែរអ្នកមីង?

ខ៖ ផ្លាស់ប្ដូរហើយចាសទៅៗហើយ វាផ្លាស់ប្ដូរត្រង់ចាស់ណឹងឯង។

ក៖ ចុះអ្នកមីងកាលនៅក្មេងអ្នកមីងធ្លាប់មានក្ដីស្រម៉ៃថាធំឡើងចង់ធ្វើអីអត់ទេអ្នកមីង?

ខ៖ ដូចអត់ចង់ធ្វើអីបើវាអត់ចេះអក្សរ បើចេះអក្សរប្រហែលចង់ខ្លះដល់ពេលអត់ចេះអក្សរមានចង់ធ្វើអី។

ក៖ ចឹងឥឡូវទាក់ទងជាមួយចំណង់ចំណូលចិត្តមីងម្ដង តើអ្នកមីងចូលចិត្តពិសារម្ហូបអ្វីជាងគេបំផុតដែរអ្នកមីងតាំងពីក្មេងដល់ឥឡូវណា? ម្ហូបណាមីងចូលចិត្តហូបជាងគេ?

ខ៖ អញតែស្លរម្ជូរត្រកួនទេ កូនចឹងដែរស្លរម្ជូរត្រកួនមួយឆ្នាំងអស់ហើយ បើថាស្លរអីឯណាឯណីទៀតអត់សូវស៊ីទេបើថាស្លរម្ជូរត្រកួនវាចូលចិត្តណាស់អាកូននោះ។

ក៖ ចុះអ្នកមីងចូលចិត្តស្ដាប់បទចម្រៀងអីទេកាលពីក្មេង?

ខ៖ ស្ដាប់បទចម្រៀនស៊ិន ស៊ីសាមុតណឹងឯង ប៉ែន រ៉ន រស់ សេរីសុទ្ធា តែសព្វថ្ងៃក៏ចូលចិត្តចាក់ស្ដាប់ដែរ។

ក៖ ចុះពេលចូលឆ្នាំ ភ្ជុំបិណ្ឌកាលពីសម័យមុនអ្នកមីងធ្លាប់បានលេងល្បែងប្រជាប្រិយអីនិងគេអត់មីង?

ខ៖ បោះអង្គុញ លេងឈូង ទាញព្រាត់ ដណ្ដើមស្លឹកឈើគ្នា។

ក៖ ចឹងមកដល់សព្វថ្ងៃនេះអ្នកមីងមានកូននិងចៅប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ បានចៅ ៦ ៧នាក់ហើយ។

ក៖ ចុះកូនប៉ុន្មាននាក់ដែរហើយអ្នកមីង?

ខ៖ ចៅបាន១មិញណឹងឯង។

ក៖ ចុះអ្នកមីងកូនអ្នកមីងមានកូនប៉ុន្មាននាក់ហើយ?

ខ៖ កូនមីង កូនមីងរាល់ថ្ងៃហី?

ក៖ បាទ។

ខ៖ មីងតូច អាប្រុស ព្រីង អាខូច ៥នាក់។

ក៖ អញ្ចឹងមកដល់ចុងបញ្ចប់នេះតើអ្នកមីងមានអ្វីចង់ផ្ដាំផ្ញើទៅកាន់កូនចៅជំនាន់ក្រោយអ្នកមីងទេ ថាតើពួកគាត់គួរតែរស់នៅបែបណា? ឬត្រូវធ្វើជាមនុស្សបែបណាក្នុងសង្គមដែរមីង?

ខ៖ ចង់ផ្ដាំកូនចៅឲ្យធ្វើមនុស្សល្អក្នុងសង្គមកុំដើរផ្លូវខុសជក់ថ្នាំកុំអីណាកូន កុំដើរលួចឆក់កុំដើរជក់ថ្នាំពិបាកណាស់ជាប់គុក បានឲ្យកូនដើរផ្លូវល្អទាំងអស់គ្នាធ្វើអំពើល្អដើរផ្លូវល្អកុំលួចឆក់គេណា ខំរៀនសូត្រក្រែងលោបានចេះដឹងបានការងារធ្វើណាកូន ក្មេងៗទាំងអស់ណឹងឯងស្ដាប់មីងណា ដើរឲ្យល្អប្រយ័ត្នណាស់កូនតែដើរមិនត្រូវតិចជាប់គុកបានសព្វថ្ងៃក៏ពេលទៅរៀនរាល់ថ្ងៃណឹងចឹងដែរ កូនក្មួយទាំងអស់ជិះម៉ូតូប្រយ័ត្នណាកូន ប្រយ័ត្ន មើលឆ្វេងមើលស្ដាំពាក់មួកសុវត្ថិភាពគ្រោះថ្នាក់ណាស់។

ក៖ បាទចឹងអ្នកមីងអរគុណច្រើនដែលបានចំណាយពេលវេលាសម្ភាសន៍ជាមួយខ្ញុំមីងណា ខ្ញុំសូមជូនពរឲ្យមីងមានសុខភាពល្អ មានសំណាងល្អ និងមានសុភមង្គលក្នុងក្រុមគ្រួសារមីងណា។

ខ៖ សាធុ។

ក៖ បាទមីង៕